# ដំរីព្ញូវ៌តក្នុងសិល្បៈខ្មែរ

នៅលើសិលាចារឹកខ្មែរបុរាណ ពាក្យដំរីមានការសរសេរខុសគ្នាដូចជា៖ ***តំរ៉ិយ*** (K.654) ***តំម្រី*** (K.388) ***តំរេ*** (K.9) ***និង តំរេយ្យ*** (K.257) ដែលខ្លះជាដំរីអំណោយរបស់ស្តេច មន្ត្រី ឬអ្នកមានដល់ទីប្រាសាទ។ ចំពោះពាក្យ ***ព្ញូវ៌ត*** ជាពាក្យសំស្រ្កឹតមានន័យសំដៅទៅលើឈ្មោះដំរីសដែលមានក្បាល៣កើតចេញពីកូរសមុទ្រទឹកដោះ ហើយព្រះឥន្ទ្របានស្នើសុំធ្វើជាយានជំនិះរបស់ទ្រង់។ ក្នុងគំនិតខ្មែរមួយចំនួន សព្វថ្ងៃគេហៅដំរីព្ញូវ៌តថា ***កណ្តឹងសាមពាន់*** ហើយក្នុងភាសាថៃហៅថា ***ឥរាវ៉ាណ***។ ***ព្ញូវ៌ត*** គឺជាស្តេចលើដំរីទាំងឡាយដែល មានសម្បុរស ភ្នែកក្រហម ភ្លុកវែងមុតចំនួន៤ (ភ្លុកនេះអាចចាក់ទម្លុះទៅក្នុងវត្ថុផ្សេងៗ) និងប្រមោយចំនួន៧។ ការចូលរួមក្នុងចម្បាំងរបស់ដំរីព្ញូវ៌តក្នុងការប្រមូលទ័ពពពក គឺក្នុងរឿងមហាភារត ត្រង់វគ្គលេបព្រៃ ***ខនដវ*** ដោយព្រះអគ្គី ក្រោមការជួយពីក្រឹស្ណៈ និងអរជុនប្រឆាំងនឹងភ្លៀងរបស់ព្រះឥន្ទ្រ។

ក្នុងសិល្បៈខ្មែរ គេឆ្លាក់ដំរីព្ញូវ៌តជាយានជំនិះរបស់ព្រះឥន្ទ្រ ភាគច្រើននៅលើផ្តៃផ្តែរ ពេលខ្លះលើហោជាង នៃទ្វារចូលខាងកើតរបស់ប្រាសាទ ជួនកាលមានក្បាល១ តែភាគច្រើនមានក្បាល៣។ ការបង្ហាញជាលើកដំបូង គឺនៅលើផ្តែរទ្វារក្រុមប្រាសាទសំបូរព្រៃគុកនាសតវត្សទី៧-៨ ឧទាហរណ៍ផ្តែរខាងកើត នៃប្រាង្គ S1 មានចម្លាក់ព្រះឥន្ទ្រគង់លើដំរីក្បាល១ អមសង្ខាងដោយក្បាច់ផ្កាបន្តទៅឆ្វេង និងស្តាំ។ សម័យអង្គរចម្លាក់ដំរីព្ញូវ៌តមានក្បាល១ ខ្លួន១ ឈរទ្រើងត្រង់ចំពីមុខ ពេលខ្លះឈរចំពីចំហៀង។ ភាគច្រើនជាដំរីក្បាល៣ ជួនកាលមានដងខ្លួនតែ១ ក្បាល៣ ជួនកាលមានខ្លួន៣ក្បាល៣ ពេលខ្លះលេចចេញពីក្បាច់កម្រងផ្កាភ្ញី ពេលខ្លះឈរនៅលើក្បាលព្រះកាល(រាហ៊ូ)។

ចម្លាក់ក្រឡោតទាបនៅថែវទិសពាយ័ព្យរបស់ប្រាសាទអង្គរវត្ត ព្រះឥន្ទ្រទ្រង់គង់នៅលើដំរីព្ញូវ៌តដែលមានក្បាលតែ១ ចូលរួមជាមួយនឹងទេពដទៃទៀតក្នុងការធ្វើចម្បាំងជាមួយនឹងពពួកអសុរ។ ក្នុងរាជ្យព្រះបាទ ជ័យវរ្ម័នទី៧ ដំរីព្ញូវ៌ត គឺគេសាងជាចម្លាក់ថ្មយ៉ាងធំ នៅផ្លូវឡើងទៅព្រះលានដំរីក្នុងបរិវេណអង្គរធំ។ ចម្លាក់ ដែលធំជាងគេបង្អស់របស់ដំរីព្ញូវ៌តក្នុងសិល្បៈខ្មែរ ឃើញមានគេឆ្លាក់នៅតាមច្រកចូលទាំង៥របស់កំពែងអង្គរធំដែលនៅតាមជ្រុងទាំង៤ នៃច្រកនីមួយៗ គឺព្រះឥន្ទ្រអមដោយស្រ្តី២នាក់ អង្គុយនៅលើដំរីក្បាល៣ ប្រមោយទាំង៣កាន់ផ្កាឈូក ហើយនៅពីក្រោមនោះមានចម្លាក់ជាសត្វត្រី ក្រពើ និងបក្សីផ្សេងៗទៀតផង។

អត្ថបទដោយ៖ លោក ***សុខ កែវសុវណ្ណារ៉ា***

ទាក់ទងទៅនឹងដំរីនេះផងដែរ តាមរយៈសិលាចារឹកសម័យមុនអង្គរបានបង្ហាញថា ទីក្រុងខ្មែរដំបូងមានឈ្មោះ ***វ្យាធបុរៈ*** (K.109) គឺមានន័យទាក់ទងទៅនឹងការទាក់ ឬការប្រមាញ់ពិសេសគឺសត្វដំរី។ មកដល់រាជ្យព្រះបាទជ័យវរ្ម័នទី៣ ព្រះអង្គជាស្តេចដែលចូលចិត្តទាក់ដំរី ហើយព្រះអង្គបានទាក់បានដំរី១ តែដំរីនោះបានរួច និងរត់ចូលព្រៃបាត់វិញ ដោយសារចង់បានដំរីនោះមកវិញ ព្រះអង្គបានសន្យានឹងទេពក្នុងសុបិន្ត ដោយការសាងព្រះបដិមា១អង្គនៅក្នុងតំបន់ដែលមានឈ្មោះថា ***វិស្ណុគ្រាម***(K.521) (ប្រាសាទគោកចកសព្វថ្ងៃ)។

ជាសង្ខេប ***ព្ធរ័ត*** នៅក្នុងសិល្បៈ និងជំនឿខ្មែរ គឺមានការពេញនិយមយ៉ាងខ្លាំងនៅសម័យអង្គរ ពិសេសគឺចាប់ផ្តើមសតវត្សទី១០ ទោះបីយើងឃើញមានបង្ហាញខ្លះៗនៅសតវត្សទី៧ ឬ៨ និងមួយចំនួនជាចម្លាក់ដំរីដែលមិនសំដៅទៅលើដំរីព្ធរ័តដែលជាយានជំនិះរបស់ព្រះឥន្ទ្រទេនៅក្នុងសតវត្សទី៩ ព្រោះជាចម្លាក់ដំរីធម្មតានៅលើផ្តែរ និងនៅតាមជ្រុងថ្នាក់ៗដែលជាខឿន (ពីរ៉ាមីត) របស់ប្រាសាទ។ ចុងសតវត្សទី៩ ដើមសតវត្សទី១០ រហូតដល់ចុងសម័យអង្គរ (ដើមសតវត្សទី១៥) ដំរីព្ធរ័តដែលគង់ពីលើដោយព្រះឥន្ទ្រត្រូវបានឆ្លាក់យ៉ាងច្រើននៅលើផ្តែរទ្វារចូលទិសខាងកើតរបស់ប្រាសាទ នៅលើហោជាង និងជារូបឈរនៅលើដីជាដើម។ រូបរាង និងសកម្មភាពរបស់ដំរីព្ធរ័តត្រូវបានគេឆ្លាក់ខុសៗគ្នាទៅតាមបែបផែននៃរចនាបទក្នុងសម័យកាលនីមួយៗ។



ក្រឹស្ណប្រយុទ្ធជាមួយសេះកេសិនលើក្បាលដំរីព្ធរ័ត
(សារមន្ទីរបាត់ដំបង)



ព្រះឥន្ទ្រគង់លើដំរីព្ធរ័ត
(ក្លោងទ្វារខាងជើងអង្គរធំ)

អត្ថបទដោយ៖ លោក **សុខ កែវសុវណ្ណារ៉ា**